# អ្នកនាំសារ

# The Messenger

21

ខែមីនា ឆ្នាំ២០០៥- ព័ត៌មានពីព្រះសហគមន៍កាតូលិក

## ៨ មីនា បុណ្យសិទ្ធិនារី



## តំណែលសិទ្ធិស្ត្រីកំពុងឈានទៅមុខ?



តើហេតុអ្វីត្រូវដូរពណ៌ស្បែកអោយស?

ទំព័រ ២



បណ្ណាល័យចល័តជួយឱ្យកុមារបានអាន

ទំព័រ ៨

សិទ្ធិស្ត្រីមានការវិវត្តន៍តាមជំនាន់

ទំព័រ ៦

# ហេតុអ្វីត្រូវដូរពណ៌ស្បែកអោយស?

**ទំនោររបស់យុវជនសម័យថ្មីគឺការនិយមប្រើប្រាស់ផលិតផលក្រែមដើម្បីឱ្យស្បែកសកាន់តែច្រើនឡើងៗ។ ពួកគេជឿថាកាលណាស្បែកកាន់តែស ក៏កាន់តែមានគេរាប់អានច្រើនដែរ។ មិនថាប្រុស ឬ ស្រីទេ ការឈ្លក់វង្វេងនេះបានក្លាយទៅជាម៉ូដសម័យទំនើបមួយ ទោះបីពួកគេដឹងថាធ្វើនេះត្រូវការចំណាយធនធានជាច្រើនយ៉ាងណាក្ដី។**


ក្រឡទ្បេដែលម្ចាស់ហាងជាអ្នកលាយផ្សំសារជាតិផ្សេងៗដើម្បីធ្វើឱ្យស្បែកស

Pictures: Davith

### ស្បែកសដ៏ពេញនិយម

ជារៀងរាល់ថ្ងៃ ចរិយាតែងតែចំណាយពេលជាងកន្លះម៉ោងក្រោយពីងូតទឹក និង រៀបចំចូលគេង ដើម្បីលាបក្រែម ឬឡេដ៏ស័ក្តិសិទ្ធិ។ នាងបានជឿជាក់ថា ធ្វើនេះ អាចឱ្យស្បែកនាងសបាន។ អស់រយៈពេលជាង ៦ខែ មកហើយ ដែលនាងបានប្រើឡេលាបលើស្បែក។ នាងបានដឹងវិធីសាស្ត្រនេះតាមរយៈមិត្តភក្តិដែលធ្លាប់រៀនសំអាងកាយជាមួយគ្នា។ ស្ថិតក្នុងវ័យ ២១ឆ្នាំ ចរិយាប្រកបការងារក្នុងមជ្ឈដ្ឋានតុបតែងកាយ។ នាងកំពុងរៀបចំ ដើម្បីបើកហាងកែសម្ផស្សមួយ ក្នុងពេលឆាប់ៗនេះ ក្រោយពីទទួលបានការបណ្ដុះបណ្ដាលអស់រយៈពេលជាច្រើនខែមក។ ក្នុងនោះនាងមិនដែលភ្លេចលក់នូវផលិតផលក្រែមធ្វើឱ្យស្បែកសជូនដល់អតិថិជននាងឡើយ។ ចរិយាពន្យល់ឱ្យដឹងថា: “មនុស្សគ្រប់រូបចង់ឱ្យស្បែកសសាច់ខ្ចីល្អ វាជារឿងធម្មតា! មនុស្សភាគច្រើនប្រើឡេលាបស្បែក ដោយសារពួកគេចង់កែអ្វី ដែលមានមកពីធម្មជាតិ”។ ទោះបីជាយុវនារីនេះ មានស្បែកធម្មតាសមរម្យហើយយ៉ាងណាក្ដី ក៏នាងនៅតែចង់ឱ្យស្បែកខ្លួនបានស្អាតប្លែកពីគេទៀតដែរ។



### ស្បែកសសំរបតាមសំលៀកបំពាក់សម័យថ្មី

កញ្ញា ញ៉ែត ថាវី ម្ចាស់ហាងសម្រស់នារីខ្មែរបាននិយាយថា ការប្រើឡេធ្វើឱ្យខ្លួនសនេះ ចាប់ផ្ដើមពេញនិយមនៅប្រទេសខ្មែរ អស់រយៈពេល ២ឆ្នាំមកហើយ។ ជាទូទៅ ម្ចាស់ហាងកែសម្ផស្សភាគច្រើនដែលទៅធ្វើការរៀនសូត្រ នៅឯប្រទេសថៃតែងពាំនាំនូវអ្វីដែលជាការពេញនិយមរបស់យុវជនថៃយកមកសាបព្រោះដាក់យុវជនខ្មែរ។ គាត់បានអះអាងថា: “ជនជាតិអាស៊ីភាគច្រើន និយមចូលចិត្តស្បែកសម៉ត់ស្អាតខុសប្លែកពីធម្មតា។ បើយើងមានស្បែកខ្មៅ យើងមិនហ៊ានបញ្ចេញសាច់ទេ ហើយក៏ពុំសូវចូលចិត្តបង្ហាញមុខក្នុងពិធីនានាដែរ”។ អំណះអំណាងបែបនេះពុំសូវជាមានទម្ងន់ប៉ុន្មានទេសំរាប់ធ្វើការពន្យល់ លើទំនោរចង់បានស្បែកស ពីព្រោះនៅមានហេតុផលមួយទៀត គឺថា យុវជន នាសម័យបច្ចុប្បន្ន ចូលចិត្តស្លៀកពាក់បញ្ចេញរាង និង បញ្ចេញសាច់ ជាពិសេសគឺការស្លៀកពាក់តាមបែបបស្ចិមប្រទេស ពោលគឺមានអាវរំាលដៃ ខោសំយេះចេញត្រគាក ឬ បែបខើចលើ ខើចក្រោម។ លើសពីនេះទៀតដែរ តាមការវិវត្តន៍នៃការរចនាម៉ូដសំលៀកបំពាក់ មនុស្សជាច្រើន បានចូលចិត្តស្លៀកពាក់បញ្ចេញសាច់ ដើម្បីបង្ហាញគ្រឿងអលង្ការនៅក្នុងពិធីនានាផងដែរ។

### ក្ដីកង្វល់ដែលមិនទាន់គិតដល់

មិនថាការលាបឡេ ឬ បកស្បែកទេ ផលប៉ះពាល់តិចនិងច្រើន ពិតជាអាចនឹងកើតមានជាក់ជាមិនខាន ប្រសិនបើការអនុវត្តន៍នោះពុំគោរពទៅតាមក្បួនវិជ្ជាជីវៈទេនោះ។ ទោះបីជា ចរិយាចង់បានសម្រស់ស្រស់ស្អាតក្ដី ក៏នាងតែងបានគិតទៅដល់ផលប៉ះពាល់របស់វាផងដែរ។ តាមពិតអស់រយៈពេលតែចន្លោះពី ២សប្ដាហ៍ ទៅ ១ខែ ប៉ុណ្ណោះក្រែមដ៏ពេញនិយមបានផ្លាស់ប្ដូរស្បែកចរិយាឱ្យសបាន។ ដោយដាក់ក្នុងក្រឡធុនមធ្យម តំលៃ ១៥ដុល្លារ ចរិយាបានប្រើប្រាស់វា ជាប់ជាប្រចាំអស់រយៈពេល ៦ខែ។ នាងបានបង្ហើបឱ្យដឹងថា: “បើយើងប្រើឡេណាដែលអាចធ្វើឱ្យស្បែកឡើងសលឿនក្នុងរយៈពេលប៉ុន្មានថ្ងៃនោះ វាអាចធ្វើឱ្យខូចស្បែកបាន។ ផលិតផលដែលមានដាក់ម្សៅជូរដើម្បីធ្វើឱ្យឆាប់បានសរហ័សនោះ វានឹងធ្វើឱ្យប៉ះពាល់សុខភាព”។ ម្ចាស់ហាងសម្រស់នារីខ្មែរបានឯកភាពទាំងស្រុងចំពោះយោបល់នេះ។ គាត់បញ្ជាក់ថា: “ឡេណាដែលធ្វើឱ្យស្បែកសឆាប់ ជាពិសេសម្សៅជូ វាក៏ធ្វើឱ្យស្បែកស្តើងឆាប់ដែរ”។ ទោះបីជា គាត់ធានាថា សំអាងការគាត់មិនមានលាយនូវផលិតផលបែបនេះក្ដី ក៏ផលិតផលគាត់នៅតែធ្វើឱ្យសលឿនក្នុងរវាងតែ ៣ថ្ងៃប៉ុណ្ណោះ។

### ការថែរក្សាស្បែកខ្លួនជារបៀបមួយសាមញ្ញ

“បើយើងមានស្បែកស្អាតហើយ តែយើងមិនចេះថែរក្សានោះ វាជារឿង១ ដែលគួរឱ្យសោកស្ដាយជាទីបំផុត”។ នេះជាសំដីរបស់កញ្ញា ស្រី ណាវ ជាបុគ្គលិកផ្នែកទីផ្សារនៃក្រុមហ៊ុនមួយ។ ទោះបីជានាងធ្វើការនៅក្រោមពន្លឺថ្ងៃស្ទើរតែគ្រប់ពេលក្ដី ក៏នាងមានវិធីសាស្ត្រក្នុងការការពារស្បែកដែរ។ វិធីការពារស្បែកឱ្យស្អាតបានយូរអង្វែងនោះ គឺត្រូវចេះពាក់មួក ពាក់អាវដៃវែង ស្រោមដៃ និង ស្រោមជើងជាដើម។ អ្វីដែលសំខាន់ជាងនេះ គឺការចេះជ្រើសរើសយកឡេការពារកំដៅថ្ងៃដែលស័ក្តិសមជាមួយនឹងស្បែករបស់យើងដើម្បីចៀសវាងកុំឱ្យកើតមានបញ្ហាផ្សេងៗ ដូចជាការកើតនូវជម្ងឺសើស្បែក ឬជម្ងឺមហារីកស្បែកជាដើម។

បូលីន ដារិដ និងមុំ គន្ធា

## តំលៃនៃព្រះអំណោយទាន

លោកឪពុកអូមែរ ហ្សីរ៉ាល់ដូ មានប្រសាសន៍ថា: “រូបកាយ និងពណ៌សំបុរគឺជាព្រះអំណោយទានព្រះជាម្ចាស់ដែលផ្ដល់ឱ្យយើង។ ទោះបីយើងមានស្បែកខ្មៅ ស ឬលឿងគឺសុទ្ធតែមានតំលៃស្មើៗគ្នា។ ល្អ ឬអាក្រក់ គឺចេញពីដួងចិត្ត និងការប្រព្រឹត្តិរបស់មនុស្សម្នាក់ៗ។ យើងត្រូវរិះគិត ថែរក្សា និងស្រលាញ់ព្រះអំណោយទាននេះ កុំភ្លើតភ្លើនតាមសម័យនិយម”។ វណ្ណា



# ជាតិគ័រទីកូអ៊ីឌឱ្យផលអាក្រក់

**ផលិតផលឡេធ្វើឱ្យស្បែកសដែលក្រុមស្រទាប់យុវវ័យមានទំនោរចូលចិត្តកំពុងរីកស្គុះស្គាយ។ នេះជាមតិរបស់វេជ្ជបណ្ឌិត ឡា ភៀវ អនុប្រធានគ្លីនិកជាតិសើស្បែក និងកាមរោគ។**

“ការដែលធ្វើឱ្យស្បែកស វាអាស្រ័យទៅតាមប្រភេទឡេដែលប្រើ។ ប្រសិនបើ នៅក្នុងឡេនោះមានលាយឡំនូវសារជាតិ Corticoïde (គ័រទីកូអ៊ីុឌ) ដែលធម្មតាធ្វើឱ្យស្បែកឆាប់សនោះ វាអាចធ្វើឱ្យស្បែកនោះខូចបាន ពីព្រោះសារជាតិនេះគេប្រើសំរាប់ព្យាបាលជំងឺតាអកនិងរមាស់ជាដើម។ បើយកទៅលាបនៅលើមុខទៀតនោះ គឺវាកាន់តែធ្ងន់ធ្ងរទៀត ដោយសារ វាអាចនឹងបណ្ដាលឱ្យស្បែកស្តើង ឃើញសរសៃឈាមតូចៗចេញច្បាស់។ ស្បែកឡើងក្រហម ត្រូវថ្ងៃដាំ។ បន្ថែមលើនេះ សារជាតិ Corticoïde អាចធ្វើឱ្យស្បែកខ្វះសមត្ថភាពការពារមេរោគផ្សេងៗ ឡើងគ្រាប់ និងធ្វើឱ្យស្បែកដុះរោម។ របៀបនេះយើងអាចសង្កេតឃើញកើតលើអ្នកប្រើម្សៅលាយ ឬ ត្រចៀកកាំសំរាប់លាបមុខ។ អ្នកប្រើប្រាស់ភាគច្រើនមានរង្វង់ភ្នែកស្អាតល្អគ្មានប៉ះពាល់អ្វីទេ ប៉ុន្តែស្បែកមុខគាត់វិញគឺយ៉ាប់ណាស់។ ចំពោះឡេលាបស្បែកនេះ ប្រសិនបើឡេនោះធម្មតាមិនចោទជាបញ្ហាអ្វីទេ! បញ្ហានៅត្រង់ថា តើឡេស្បែកសនោះមានលាយ នូវសារជាតិអ្វីផ្សេងដែរ ឬអត់? ពីព្រោះថាសព្វថ្ងៃ ម្ចាស់ហាងកែសម្ផស្សក៏លាយ រីឯអ្នកប្រើប្រាស់ក៏លាយ។ ចំពោះផលិតផលឡេដែលចេញមកពីរោងចក្រ ប្រសិនអ្នកផលិតមិនគោរពក្រមសីលធម៌វិជ្ជាជីវៈទេ គេអាចលាយសារជាតិនេះពីប្រទេសគេមកតែម្ដង។ ពិតមែន ឡេលាបស្បែកសព្វថ្ងៃធ្វើឱ្យស្បែកសលឿន! ប៉ុន្តែ បើប្រើរយៈពេលយូរបន្តិច វាអាចនឹងមានផលប៉ះពាល់។ សូមបញ្ជាក់ថា ប្រសិនបើស្បែកខូចធ្ងន់ហើយ ពិបាកកែណាស់! សភាពស្រាលអាចព្យាបាលបាន ប៉ុន្តែ វាបំផ្លាញនូវពេលវេលា និងទ្រព្យសម្បត្តិ។ អ្វីដែលគួរឱ្យបារម្ភពេលនេះ គឺកម្មការិនីរោងចក្រកាត់ដេរ ដែលតែងតែចង់បានឱ្យស្បែកស ហើយក៏ទៅទិញផលិតផលលាយក្នុងតំលៃថោកដែលនឹងធ្វើឱ្យខូចស្បែក”។

### ភាពថ្លៃថ្នូរមិនស្ថិតនៅលើស្បែកស

កញ្ញា ហួត សុជាតា មិនសប្បាយចិត្តឡើយចំពោះការនាំគ្នាផ្ដើលប្រើប្រាស់ផលិតផលធ្វើឱ្យស្បែកឆាប់ស។ នេះជាយោបល់របស់នាង: “ស្បែកសគឺសំរាប់អ្នកមានអាជីពលក់សម្រស់នៅក្នុងសង្គម ដូចជា តារាភាពយន្ត ឬអ្នកចំរៀង។ ប៉ុន្តែ បើយើងជាមនុស្សសាមញ្ញទេនោះ ខ្ញុំគិតថា នេះគឺជាគំនិតដ៏ឆ្កួតលីលា ដែលចង់ធ្វើឱ្យស្បែកស។ វាពុំបានផ្ដល់ប្រយោជន៍អ្វីទេក្រៅតែពីខាតពេលវេលានិងលុយកាក់។ ខ្ញុំយល់ស្របចំពោះការលាបឡេការពារកំដៅថ្ងៃ ប៉ុន្តែ មិនមែនឡេធ្វើឱ្យស្បែកឆាប់សនោះទេ។ ជាធម្មតាទេដែលយើងស្រឡាញ់អ្វីដែលផ្ទុយពីធម្មជាតិរបស់ខ្លួន វាមិនខុសអ្វីអំពីជនជាតិអឺរ៉ុបដែលមានស្បែកស តែបែរជាទៅអាំងថ្ងៃនៅក្រោមពន្លឺព្រះអាទិត្យដើម្បីធ្វើឱ្យស្បែកពួកគេឡើងខ្មៅទៅវិញនោះ”។

បូលីន ដារិដ


លោក ឡា ភៀវ វេជ្ជបណ្ឌិតជម្ងឺសើស្បែកនិងកាមរោគ។

ឆ្លងកាត់ជាច្រើនជំនាន់មកហើយ ស្ត្រីខ្មែរហាក់បីដូចជា មិនមានសិទ្ធិស្មើនឹងបុរសឡើយ។ គេតែងចាត់ទុកមនុស្សស្ត្រីគឺជាភេទទន់ខ្សោយ និងពុំមានសមត្ថភាពដូចបុរសទេ។ ប៉ុន្តែនាពេលបច្ចុប្បន្ន គំនិតទាំងនេះកំពុងតែប្រែប្រួលបន្តិចម្តងៗ។



សមាជិកបីនាក់នៃគ្រួសារ១ដែលរស់នៅឆ្លងកាត់សម័យកាលទាំងបី

# សិទ្ធិស្ត្រីមានការវិវត្តន៍តាមជំនាន់

## ស្ត្រីក្នុងសម័យអាណានិគមបារាំង

សម័យអាណានិគមបារាំង ស្ត្រីមិនមានសិទ្ធិគ្រប់គ្រាន់ទេនៅក្នុងគ្រួសារ។ ការអប់រំកូនស្រី ក៏ដូចជាការផ្តល់សិទ្ធិឱ្យពួកគេ គឺមានភាពអយុត្តិធម៌។ ឪពុកម្តាយនិយមផ្តល់សិទ្ធិកូនប្រុសច្រើនជាងកូនស្រី ដូចជាបញ្ជូនកូនប្រុសឱ្យទៅរៀន ហើយទុកកូនស្រីនៅផ្ទះជាដើម។ ជាមួយនឹងមាត់កំពុងតែទំពាស្លាលោកយាយ អ៊ុំ នៅ ដែលមានអាយុ ៧៦ ឆ្នាំ ជាស្ត្រីម្នាក់ដែលកើតក្នុងសម័យអាណានិគមបារាំង។ គាត់បានមានប្រសាសន៍ខ្លាំងៗថា:
"ម្តាយខ្ញុំមិនផ្តល់សិទ្ធិឱ្យខ្ញុំបានទៅរៀនទេ។ គាត់ថាមិនបាច់ចាំចេះអ្វីទេនាំគ្នាធ្វើស្រែ ហើយលក់វាទិញមាសទុកទៅ។ វាស្រួលហើយ"។
ចំពោះការរើសគូស្រករក៏ដូច្នេះដែរ គឺឪពុកម្តាយជាអ្នករៀបចំទុកដាក់គូស្រករឱ្យកូនស្រី។ លោកយាយបានបញ្ចេញសំដីហាក់ដូចជាខឹងថា: "ខ្ញុំមិនដែលស្គាល់តា (ប្តី) ខ្ញុំទេ គឺម្តាយខ្ញុំលើកខ្ញុំឱ្យទៅគាត់ដោយមិនបានសួរខ្ញុំមុន"។ គាត់ក៏បានបន្ថែមទៀតថា: "ទោះបីជាមានការរំលោភសិទ្ធិដូច្នេះក៏ដោយ ក៏នៅមានកូនស្រីមួយចំនួនមិនយល់ព្រមនឹងការគាបសង្កត់ មកលើសិទ្ធិរបស់ពួកគេដែរ គឺពួកគេហ៊ានដល់ទៅប្រកែករើបំរាស់ មិនព្រមរៀបការ ដែលទង្វើនេះចាស់ជំនាន់នោះហៅថាកូនស្រីមិនដើរតាមគន្លងធម៌ ឬជាស្រីខាតលក្ខណ៍ដែលធ្វើឱ្យឪពុកម្តាយខ្មាស់គេ"។



លោកយាយ អ៊ុំ នៅ "សម័យបារាំង ខ្ញុំមិនដែលឃើញមានប្រារព្ធពិធីសិទ្ធិនារីអ្វីទេ ខ្ញុំទើបតែឮនៅសម័យនេះឯង។ ខ្ញុំយល់ថាស្ត្រីត្រូវតែមានសិទ្ធិតវ៉ាជាមួយអ្នកដទៃ ពីព្រោះនៅសម័យមុននោះ ខ្ញុំតែងឃើញថាពេលមានប្រជុំម្តងៗ គេហៅតែបុរសទៅទេ ចំណែក នារីមិនអាចទៅចូលរួមបានឡើយ"។

Photo: Davith

## ស្ត្រីសម័យមុន និងក្នុងរបបប៉ុលពត

អ្នកស្រី ឈិត ប៊ុនផ្កា ជាកូនស្រីរបស់លោកយាយ អ៊ុំ នៅ។ ស្ថិតក្នុងវ័យពាក់កណ្តាលមនុស្ស គាត់បានក្លាយទៅជាស្ត្រីម្នាក់ ដែលមិនចេះអក្សរ ពីព្រោះ កាលពីក្នុងវ័យកុមារភាព គាត់មិនបានទៅសាលារៀនឡើយ។ ម្តាយគាត់ធ្វើនំ ឱ្យគាត់យកទៅលក់ដើម្បីយកប្រាក់ទៅផ្គត់ផ្គង់ការរៀនសូត្ររបស់ប្អូនប្រុស។ លើសពីនេះ គាត់ក៏ត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុរស ដែលឪពុកម្តាយគាត់ជាអ្នករៀបចំឱ្យ។ ដោយនៅនឹងដៃកំពុងតែកាន់ក្រាស់សិតសក់ជាប់ជាមួយផងនោះ អ្នកស្រីបានមានប្រសាសន៍ថា: "ខ្ញុំយល់ថា ការផ្តល់សិទ្ធិទៅឱ្យនារីៗ គឺមានលក្ខណៈប្រសើរណាស់។ ស្ត្រីត្រូវមានសិទ្ធិស្មើភាពគ្នាជាមួយបុរស។ យើងត្រូវតែធ្វើការគោរពគ្នាទៅវិញទៅមក តែក៏មិនត្រូវប្រើសិទ្ធិនោះឱ្យហួសហេតុពេកដែរ"។



អ្នកស្រី ឈិត ប៊ុនផ្កា "ខ្ញុំមិនដែលឮនិងឃើញមាននរណាប្រារព្ធធ្វើទិវាសិទ្ធិនារីនេះក្នុងរបបប៉ុល-ពត ហើយនារីក៏មិនមានសិទ្ធិ និងសេរីភាពដូចសង្គមសម័យឥឡូវដែរ។ ពីមុនសូម្បីសិទ្ធិក្នុងការតវ៉ាក៏គ្មានផង ហើយការតវ៉ានោះបើគ្មានហេតុផលសមស្របទេ គឺមិនហ៊ានតវ៉ាដែរដោយខ្លាចអំណាចរបស់គេ"។

គាត់បានបន្តថា: "អ្វីៗ ដែលម្តាយរបស់ខ្ញុំមិនបានផ្តល់សិទ្ធិឱ្យរូបខ្ញុំនោះ គឺជាកំហុសមួយ ពិសេស គឺការរើសគូស្រករ។ ដូច្នេះ ខ្ញុំនឹងមិនយកសិទ្ធិ និងទំលាប់របស់ម្តាយខ្ញុំមកប្រើជាមួយកូនស្រីខ្ញុំទេ។ ខ្ញុំនឹងផ្តល់សិទ្ធិដល់គេ ទាំងការសិក្សា ការដើរកំសាន្ត និងការរើសគូស្រករផងដែរ តែមិនអាចធ្វើឱ្យជ្រុលជ្រួសហួសហេតុពេកដែរ"។

## នារីនៅក្នុងសម័យបច្ចុប្បន្ន

ជាមួយនឹងសម្លៀកបំពាក់នៅផ្ទះ កញ្ញា ហែម ចាន់សុធារី បានទទួលស្វាគមន៍រាក់ទាក់ភ្ញៀវជាមួយទឹកមុខយ៉ាងស្រស់ស្រាយ។ កញ្ញា សុធារី មានអាយុ១៩ឆ្នាំ ជាសិស្សវិទ្យាល័យទួលទំពូង។ នាងគឺជានារីម្នាក់ដែលមានសំណាង បានមកកើតនៅក្នុងសម័យមួយ ដែលសង្គមបានផ្តល់សិទ្ធិ និងយកចិត្តទុកដាក់ចំពោះនារីភេទ។ នាងមានការយល់ដឹងច្រើនអំពីសិទ្ធិមនុស្ស ជាពិសេសសិទ្ធិនារី ពីព្រោះមានក្នុងកម្មវិធីសិក្សានៅឯសាលារៀន។ ធារី បានបញ្ចេញនូវទស្សនៈរបស់នាងថា: "នារីត្រូវតែមានសិទ្ធិស្មើនឹងបុរស ពោលគឺ មិនអាចឱ្យដូចនៅក្នុងសម័យជំនាន់ចាស់បុរាណនោះទេដែលពីមុនគេច្រើននាំគ្នាយល់ថា នារីវិលចង្ក្រានមិនជុំ តែឥឡូវជាសម័យអ៊ិនធឺណេត ដែលនារីមានសមត្ថភាពអាចធ្វើអ្វីៗបានដូចបុរសដែរ ហើយជួនកាល ក៏អាចធ្វើបានលើសពីបុរសផង"។ នាងបានបន្ថែមទៀតថា នៅសាលារៀននាងធ្វើការទំនាក់ទំនង ដោយប្រើសិទ្ធិស្មើគ្នា មិនប្រកាន់វណ្ណៈ ឬជាតិសាសន៍ឡើយ ឯនៅក្នុងក្រុមគ្រួសារ គឺនាងប្រើប្រាស់សិទ្ធិ ដោយគោរពឪពុកម្តាយក្នុងភាព



កញ្ញាហែម ចាន់សុធារី "សព្វថ្ងៃនេះខ្ញុំមានសិទ្ធិសេរីភាពគ្រប់គ្រាន់ទាំងនៅក្នុងគ្រួសារ សាលា និងក្នុងសង្គម។ ប៉ុន្តែមិនមែនមានន័យថាយើងមានសិទ្ធិ ហើយចេះតែប្រើតាមតែអំពើចិត្តរបស់យើងនោះដែរ គឺត្រូវប្រើឱ្យសមហេតុសមផលផងដែរ។ ខ្ញុំគិតថានៅពេលអនាគត នារីនឹងអាចក្លាយជាអ្នកគ្រប់គ្រងប្រទេសជាតិបានដូចជាបុរសដែរ"។

ជាស្រីគ្រប់លក្ខណ៍។ នាងយល់ថា សព្វថ្ងៃ នាងមានសិទ្ធិគ្រប់គ្រាន់ក្នុងការបញ្ចេញមតិយោបល់ទាំងនៅក្នុងគ្រួសារ និងក្នុងសាលា ហើយបើចង់ធ្វើអ្វីៗ គឺនាងមានសិទ្ធិធ្វើបាន។
តាមរយៈសំដីអះអាងរបស់ជីដូន ម្តាយ និង កូនស្រីខាងលើនេះធ្វើឱ្យយើងមើលឃើញនូវទិដ្ឋភាពនៃសង្គមខ្មែរ ពិសេស សិទ្ធនារីដែលឆ្លងកាត់តាមសម័យកាល។ ឆ្លងតាមរយៈនេះ មតិដែលយល់ថាស្ត្រីមានភាពទន់ខ្សោយឬគ្មានសមត្ថភាពនោះកំពុងតែឈានទៅរកការសាបរលាបជាបណ្តើរៗហើយ។ ដូច្នេះ ដើម្បីចូលរួមចំណែកក្នុងការលើកស្ទួយសិទ្ធនារី ការដាក់បញ្ញាបចូលគោលការណ៍គោរពសិទ្ធគ្នាទៅវិញទៅមក រវាងបុរស និងនារីនៅក្នុងមជ្ឈដ្ឋានគ្រួសារ ក៏ដូចជាមជ្ឈដ្ឋានសង្គម គឺជាកត្តាចាំបាច់មួយ ដែលប្រជាជនទូទៅគួររួមគ្នាអនុវត្តដោយខានពុំបាន។
ទន្ទឹមគ្នានេះដែរ ការផ្តល់លទ្ធភាពឱ្យស្ត្រីបានរៀនសូត្រក៏គឺជាគន្លឹះដ៏ចំបងមួយក្នុងការលើកស្ទួយដល់ជីវភាពរស់នៅរបស់ស្ត្រីផងដែរ។

មុំ គន្ធា និងបូលីន ដាវីដ

## គោលនយោបាយលើកស្ទួយដល់សិទ្ធិនារី

**អប់រំស្ត្រី:** ដោយសង្កេតឃើញថាស្ត្រីចំនួន ៥២% ជាអនក្ខរជន (អ្នកមិនចេះអក្សរ) ក្រសួងកិច្ចការនារីមានគោលនយោបាយធ្វើឱ្យស្ត្រីបានរៀនសូត្រ និងឱ្យមានជំនាញច្បាស់លាស់ដើម្បីប្រកបរបរចិញ្ចឹមជីវិត។
**សុខភាព:** ក្រសួងនឹងចូលរួមសហការជាមួយក្រសួងពាក់ព័ន្ធដូចជាក្រសួងសុខាភិបាលដោយធ្វើយ៉ាងណាធ្វើការកាត់បន្ថយអត្រាស្លាប់ពេលឆ្លងទន្លេ និងកាត់បន្ថយការចម្លងជំងឺអេដស៍ពីស្វាមីមកឱ្យភរិយា និងកូនៗ។
**ច្បាប់:** បង្កើតច្បាប់ដាក់ទោសបុរសឬជនដែលប្រើអំពើហិង្សាដាក់គ្រួសារ និងធ្វើច្បាប់ណែនាំអប់រំដល់ក្រុមគ្រួសារឱ្យដឹងពីសុភមង្គលក្នុងគ្រួសារដោយធ្វើយ៉ាងណាឱ្យការប្រើអំពើហិង្សាលែងមាននៅក្នុងគំនិតរបស់បុរសជាស្វាមី។
**ផ្តល់អំណាចសេដ្ឋកិច្ចជូនស្ត្រី:** បង្កើនការបង្រៀនស្ត្រីដែលគ្មានលទ្ធភាព ឬគ្មានចំណេះដឹងឱ្យមានជំនាញមានការងារធ្វើដើម្បីឱ្យស្ត្រីអាចរកប្រាក់កំរៃបានដោយខ្លួនឯង។
**ស្ត្រី និងសេចក្តីសំរេច (ស្ត្រីអភិបាលកិច្ច):** ផ្តល់សិទ្ធិឱ្យស្ត្រីអាចធ្វើសេចក្តីសំរេចចិត្តទៅលើហេតុការអ្វីមួយបាន។
សម្រង់កិច្ចសម្ភាសន៍របស់លោកជំទាវ អ៊ឹង កន្ថាផាវី តាមទូរទស្សន៍ CTN។

## សំដីពីអង្គការ

## តួលេខនារីភេទកំពុងរងគ្រោះ

តាមរបាយការណ៍របស់សមាគម អាដហុក នៅឆ្នាំ ២០០៤ បានបង្ហាញឱ្យឃើញថា អំពើហិង្សានៅក្នុងគ្រួសារ មានចំនួន៤៣៦ករណី ក្នុងនោះ៦៩% កើតឡើងនៅលើគ្រួសារដែលជីវភាពមានការខ្វះខាត និងក្រីក្រ។ ចំណែកអំពើរំលោភសេពសន្ថវៈបានកើតឡើង ចំនួន ៣២៦ករណី។ ការជួញដូរភេទមានចំនួន៣៦ករណីដែលមានជនរងគ្រោះជានារីអាយុ១៨ឆ្នាំចំនួន៣៦នាក់ស្មើនឹង៥៥.៣៨%។ តួលេខនេះ គឺកើនឡើង ៥.៣៨% បើប្រៀបធៀបទៅនឹងឆ្នាំ២០០៣ដែលមានតែ៥០%នោះ។
លោកស្រី លឹម មុនី ប្រធានផ្នែកការពារសិទ្ធិនារីរបស់សមាគម អាដហុក បានឱ្យដឹងថា ភាពក្រីក្រ ការហូរចូល និងប្រើប្រាស់គ្រឿងញៀន ការធ្លាក់ចុះនៃសីលធម៌សង្គម និងកង្វះការអនុវត្តន៍ច្បាប់របស់មន្ត្រីនៅមានកំរិត ជាមូលហេតុដែលនាំឱ្យស្ត្រីទទួលរងអំពើជួញដូរផ្លូវភេទ និង ការរំលោភបំពាន។

## មូលហេតុចំបងនៃអំពើហិង្សា

តាមរបាយការណ៍នៅឆ្នាំ២០០៤ របស់អង្គ-ការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានឱ្យដឹងថាអំពើហិង្សាក្នុងគ្រួសារ បានកើតមានចំនួន ៨៨២ករណី។ កញ្ញា ប៉ាល់ វណ្ណារី ជាបុគ្គលិកផ្នែកស៊ើបអង្កេតរឿងក្តីនៃអំពើហិង្សា ក្នុងគ្រួសាររបស់អង្គការនេះនិយាយថា: "អំពើហិង្សាដែលកើតមាននេះបណ្តាលមកពីបញ្ហាចំបងចំនួនបី ទី១ គឺប្តីអាងអំណាចនៅក្នុងគ្រួសារ ទី២ប្រទេសមិនទាន់មានច្បាប់ស្តីអំពីការទប់ស្កាត់នូវអំពើហិង្សាក្នុងគ្រួសារ និងទី៣ គឺបញ្ហា និងនិទណ្ឌភាព (ការរួចខ្លួនពីការផ្តន្ទាទោសពីសំណាញ់ច្បាប់)"។

សំ វ៉ានី

# បណ្ណាល័យចល័តជួយឱ្យកុមារបានអាន

ជារៀងរាល់ព្រឹក រថយន្តចល័តពណ៌សធ្វើដំណើរត្រាច់ចរតាមតំបន់ជាយក្រុងភ្នំពេញ។ រថយន្តដែលត្រូវបានកែច្នៃធ្វើជាបណ្ណាល័យចល័តទាំងនេះតែងទៅឈប់ នៅតាមសង្កាត់ ឬភូមិក្រីក្រមួយចំនួន។ ដោយសារហេតុនេះហើយទើបកុមារៗ អាចមានឱកាសបានស្តាប់រឿងនិទាន លេងល្បែងអប់រំ និងអានសៀវភៅ។ល។



ក្មេងប្រុសរូបនេះកំពុងតែមានអារម្មណ៍ជក់ចិត្តទៅនឹងការអានសៀវភៅរឿងព្រេងនិទានដែលប្រកបទៅដោយរូបភាពពណ៌ធម្មជាតិ និងមានការរចនាទំព័រដ៏រស់រវើកក្រោយពេលដែលរថយន្តបណ្ណាល័យចល័តបើកបរទៅដល់ភូមិរបស់គេ។

Photo: Davith

### ដំណើររបស់បណ្ណាល័យនៅភ្នំពេញ

ថ្ងៃនេះ ដោយចេញដំណើរឆ្ពោះទៅកាន់ភាគខាងលិចនៃរាជធានីភ្នំពេញ រថយន្តចល័តមួយគ្រឿងបានបោះពួយលើផ្លូវគ្រួសក្រហមដើម្បីទៅភូមិត្រពាំងពារ ខណ្ឌដង្កោរ។ ដូចរៀងរាល់ថ្ងៃច័ន្ទមុនៗដែរ មានកុមារប្រហែល៣០នាក់ តែងអង្គុយចោមរោម ចាំលោក "គ្រូ" របស់គេ នៅក្នុងអាស្រមសាលាបុណ្យក្នុងភូមិ។ "ការជ្រើសរើសកន្លែងត្រូវមានការសហការ និងយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចផងដែរមុននឹងចាប់ផ្តើមសកម្មភាព"។ នេះជាប្រសាសន៍របស់លោក យៀវ សម្បត្តិ អ្នកបើកបររថយន្ត និងជាបណ្ណារក្សរថយន្តចល័តទី៤របស់អង្គការស៊ីប៉ា។ រថយន្តចល័តនេះកំពុងមានដំណើរការក្នុងភូមិចំនួន១០ អស់រយៈពេលមួយឆ្នាំកន្លងមកហើយ។ ពេលបច្ចុប្បន្នក្នុងក្របខ័ណ្ឌកម្មវិធីអប់រំក្រៅប្រព័ន្ធអង្គការស៊ីប៉ាមានបណ្ណាល័យចល័ត ចំនួន៤ ដែលផ្លាស់ទី ក្នុងភូមិចំនួន ៥៤កន្លែង ខាងក្រៅរាជធានីភ្នំពេញ។

### រៀបចំក្រាលកន្ទេល និងលាងទឹកសំអាតដៃ

បណ្ណាល័យចល័តតែងបានទទួលការស្វាគមន៍ពីកុមារ ព្រោះការអានសៀវភៅ ឬលេងល្បែងផ្សេងៗ ពុំមានយកប្រាក់ឡើយ។ ដំបូងលោកគ្រូបណ្ណារក្សរៀបចំក្រាលកន្ទេល និងឡាំងសៀវភៅ និងគាត់ស្នើអោយកុមារទាំងអស់ទៅលាងដៃជាមុនសិន ទើបពួកគេអាចចាប់ផ្តើមអានសៀវភៅ ឬលេងល្បែងកំសាន្តបាន។ បន្ទាប់មកបណ្ណារក្សចាប់ផ្តើមអានរឿងនិទានឱ្យកុមារស្តាប់ ដោយមានការបង្ហាញនូវ រូបភាពនានាទៀតផង។ សំរាប់ថ្ងៃនេះ រឿងនិទានមានចំណងជើងថា ប្រវត្តិភ្នំយ៉ាត នៅក្រុងប៉ៃលិន។ ក្មេងៗអង្គុយស្តាប់ចំហមាត់ដោយជក់ចិត្តបំផុត។ លើសពីនេះទៀត ពួកគេអាចចូលរួមឆ្លើយសំណួររបស់លោកគ្រូជុំវិញចំណេះដឹងអំពីភូមិ-វិទ្យា ធម្មជាតិ និងវប្បធម៌ជាដើម។

### គំនូរផាត់ពណ៌ និងល្បែងអប់រំ

ក្រោយមកបណ្ណារក្សប្រាប់អោយក្មេងៗ លេងល្បែងវិ:គិត បត់ក្រដាស និងគូរគំនូរ។ លោក យៀវ សម្បត្តិ បានពន្យល់ឱ្យដឹងថា: "ពេលដែលមានក្មេងមកច្រើនពេក ខ្ញុំស្នើឱ្យពួកគេលេងល្បែងផ្សេងទៀត ចៀសវាងកុំឱ្យពួកគេធុញទ្រាន់ហើយត្រលប់ទៅផ្ទះវិញ"។ សំរាប់កុមារ ការចូលរួមក្នុងសកម្មភាពអំណានរបស់បណ្ណាល័យរៀងរាល់ថ្ងៃច័ន្ទគឺជាការទន្ទឹងរងចាំក្នុងរយៈពេលពេញមួយសប្តាហ៍។ កុមារី ស្រីនាង អាយុ ១២ឆ្នាំ បានមកជាមួយប្អូនប្រុសដែរ។ នាងបានប្រាប់ឱ្យដឹងថា: "ខ្ញុំមកទីនេះបានបីដងហើយ ខ្ញុំចូលចិត្តមកគូររូបផាត់ពណ៌គ្រប់ប្រភេទជាមួយនឹងមិត្តភក្តិ។ នៅផ្ទះ ខ្ញុំអផ្សុកណាស់ជាមួយនឹងទូរទស្សន៍។ ចំណែក កុមារា ពុទ្ធ មិថុនា អាយុ ១១ឆ្នាំ ក៏រីករាយផងដែរ ជាមួយមិត្តភក្តិក្នុងពេលជួបជុំគ្នាអានសៀវភៅ។ ក្មេងប្រុសដែលមានឪពុកគឺជាអ្នករត់ម៉ូតូឌុបរូបនេះបានបញ្ជាក់ឱ្យដឹងថា: "នៅផ្ទះ ខ្ញុំគូររូបតែលើជញ្ជាំងផ្ទះទេ។ នៅទីនេះ ខ្ញុំអាចរកបានក្រដាស និងប្រដាប់ផាត់ពណ៌។ ហើយខ្ញុំសប្បាយណាស់ពេលមកលេងបែបនេះជាមួយមិត្តភក្តិ"។ កុមារានេះ មិនខុសពីក្មេងនៅក្នុងភូមិទេ ដោយសារ ប្រាក់ចំណូលនៅក្នុងគ្រួសារស្តួចស្តើងពេក ធ្វើឱ្យឪពុកម្តាយរបស់គេគ្មានលទ្ធភាពទិញសៀវភៅឱ្យគេអានកំសាន្ត។ សំណាងល្អដែលភាពក្រីក្រពុំបានបង្អាក់ការសិក្សារបស់គេ យ៉ាងហោចណាស់កុមារានេះមានបណ្ណាល័យចល័តសំរាប់ផ្តល់សៀវភៅ និងល្បែងកំសាន្តដល់គេជារៀងរាល់សប្តាហ៍។ ពិតមែន! បរិយាកាសរបស់បណ្ណាល័យចល័តមានលក្ខណ:ខុសប្លែកពីលំនៅដ្ឋាន។ នៅលើកន្ទេលក្មេងៗអង្គុយផ្តោះប្តូរយោបល់ ផ្តុំរូបសត្វ ព្រមទាំងចែករំលែកសំភារ:គំនូរដោយគ្មានឈ្លោះប្រកែកគ្នាឡើយ។ ដូចនេះ ពេលឃើញបណ្ណាល័យចល័ត ចូរប្អូនៗកុមារកុំរុញរាមកអានសៀវភៅ។

ប៊ូលីន ដាវិដ

### តើបណ្ណាល័យចល័តជាអ្វី?

បណ្ណាល័យចល័តត្រូវបានកែច្នៃពីរថយន្តដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយដើម្បីផ្តល់សៀវភៅឱ្យក្មេងអាន និងខ្ចី។ បណ្ណាល័យនេះលេចរូបរាងឡើងទន្ទឹមពេលដែលមានការរីកចំរើនក្នុងវិស័យផលិតរថយន្តក្នុងអំឡុងពេលក្រោយសង្គ្រាមលោកលើកទី១។ តាមបណ្តាប្រទេសនានានៅអឺរ៉ុបបណ្ណាល័យចល័តជាសេវាកម្មមួយរបស់រដ្ឋដើម្បីបំរើសេចក្តីត្រូវការរបស់ប្រជាជន។ លើសពីនេះទៅទៀត រថយន្តចល័តនេះក៏បានឱ្យបណ្ណាល័យនានានៅក្នុងភូមិខ្ចីសៀវភៅផងដែរ។

## បញ្ហាអន្តរជាតិ

# ថាក់ស៊ីនដឹកនាំតាមប្រជាធិបតេយ្យរឹងត្អឹង

កាលពីដើមខែកុម្ភៈ ប្រទេសថៃបានរៀបចំធ្វើការបោះឆ្នោតជាតិមួយដែលមានគណបក្សនយោ-បាយ ចំនួន២០ និងអ្នកបោះឆ្នោតចំនួន ៤៤.៨លាននាក់មកចូលរួម។

គណបក្សសំខាន់ៗចំនួន៤ ដែលនឹងទទួលនូវអសនៈ (កៅអី) ទាំង៥០០ នៅក្នុងសភាជាតិ មានគណបក្សថៃស្រឡាញ់ថៃ គណបក្សប្រជាធិបតេយ្យ គណបក្សជាតិថៃ និងគណបក្សមហាជន។ គណបក្សថៃស្រឡាញ់ថៃបានទទួលការគាំទ្រពីប្រជាជនយ៉ាងខ្លាំងក្លា ដែលគេរំពឹងថានឹងទទួលបានអសនៈចំនួន៣៥៩។ នេះមានកំណើនបើប្រៀបធៀបទៅនឹងអសនៈចំនួន២៤៨កាលពីការបោះឆ្នោតនាឆ្នាំ២០០១។ លោក ប៉ានីតាន វ៉ឌ្ឍនយ៉ាងន អ្នកវិភាគសន្តិសុខនៅមហាវិទ្យាល័យទំនាក់ទំនងអន្តរជាតិនៃសាកលវិទ្យាល័យ ជូឡា ឡុងកន បានលើកឡើងនូវហេតុផល៣នៅពីក្រោយជ័យជំនះ ដ៏មានប្រជាប្រិយភាពរបស់គណបក្សថៃស្រឡាញ់ថៃមានដូចជា: ការបង្កើនរចនាសម្ព័ន្ធសមាជិក និងសកម្មជនគណបក្ស ការកើនឡើងនៃយុវជនអ្នកគាំទ្រ និងប្រសិទ្ធិភាពនៃការអនុ-វត្តន៍គោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួន។ ក្រុមអ្នកវិភាគនយោបាយខ្លះទៀតបានវាយតំលៃថា ជោគជ័យរបស់គណបក្សនេះគឺដោយសារ លោក ថាក់ស៊ីន បានបំពេញបេសកកម្មបំរើជាតិ ប្រកបទៅដោយសមត្ថភាពខ្ពស់ គឺផ្តើមចេញពីការបញ្ចប់មហាវិបត្តិសេដ្ឋកិច្ច នាឆ្នាំ១៩៩៧។ លោកបានធ្វើយុទ្ធនាការកំទេចរាល់សកម្មភាពជួញដូរគ្រឿងញៀនដែលសម្លាប់ជនសង្ស័យជាង ២០០០នាក់។ លោកក៏បានរក្សាស្ថេរភាពនយោបាយសំរាប់អំពើហិង្សានៅភាគខាងត្បូងប្រទេសជាពិសេសនៅស្រុកតាកបៃនៃខេត្តណាតរ៉ាត់ធីវ៉ាត់។ លើសពីនេះទៀត ក្រោយមហាវិនាសកម្មរលកយក្សស៊ូណាមិ លោកបានដោះស្រាយស្ថានការណ៍នេះយ៉ាងយកចិត្តទុកដាក់និងទាន់ពេលវេលាដោយប្រើថវិកាជាតិ និងមូលនិធិសប្បុរសជនជួយដល់ជនរងគ្រោះ និងកសាងហេដ្ឋារចនា[illegible]។

សំ វ៉ានី



### ជីវប្រវត្តិរបស់លោកថាក់ស៊ីន

លោកថាក់ស៊ីន ស៊ីណាវ៉ាត្រាកើតថ្ងៃទី២កក្កដា ១៩៤៩ ខេត្តឈៀងម៉ៃ។ លោកគឺជាអ្នកមានបំផុតនៅថៃជាមួយនឹងទឹកប្រាក់ប្រហែល២ពាន់លានដុល្លារ។ លោកបានបង្កើតនូវគណបក្សថៃស្រឡាញ់ថៃឆ្នាំ១៩៩៨។

# ប៉េតង់ត្រៀមដណ្ដើមពាន

**នៅកម្ពុជា កីឡាប៉េតង់មានការរីកចំរើនជាខ្លាំង។ ចាប់តាំងពីឆ្នាំ១៩៩៣ កីឡាករប៉េតង់ខ្មែរដណ្ដើមបានមេដាយជាច្រើនសំរាប់ជាតិពីឆាកអន្តរជាតិ។ លើកនេះគឺត្រូវត្រៀមដណ្ដើមពាន Pan Pacific។**



Photo: P. Samphy



កីឡាការិនីខ្មែរនិងមេដាយមាស នៃកីឡាស៊ីហ្គេមនៅប្រទេសវៀតណាមកាលពីឆ្នាំ២០០៣

ពានរង្វាន់ Pan Pacific (ផាន ប៉ាស៊ីភិច) គឺជាពានរង្វាន់មួយក្នុងចំណោមពានរង្វាន់អន្តរជាតិផ្សេងៗទៀត សំរាប់កីឡាប៉េតង់។ តាមពិតពាននេះត្រូវបានប្រទេសសិង្ហបុរី និងប្រទេសជប៉ុនឯកភាពគ្នាផ្ដួចផ្ដើមគំនិតបង្កើត ហើយរៀបចំធ្វើឡើងតែនៅប្រទេសវៀតណាមប៉ុណ្ណោះ។ ក្រោយពេលទទួលដំណឹងថាពានរង្វាន់នេះនឹងប្រារព្ធពីថ្ងៃទី១១ ដល់ថ្ងៃទី១៤ មីនា ឆ្នាំ២០០៥នេះ សហព័ន្ធកីឡាប៉េតង់ខ្មែរបានធ្វើការត្រៀមលក្ខណៈមួយចំនួនដើម្បីដណ្ដើមយកជ័យ។

កីឡាករប៉េតង់ទាំងអស់ដែលសហព័ន្ធបានគ្រោងនឹងបញ្ជូនទៅឱ្យចូលរួមប្រកួតមានទាំងអស់ចំនួន ៤ក្រុម ដែលក្នុងនោះមានកីឡាករ២ក្រុមរួមមានគ្នា៦រូប និងកីឡាការិនី២ក្រុមទៀតមានគ្នា៤រូបផងដែរ ព្រមជាមួយគ្រូបង្វឹក២នាក់ និងប្រធានគណៈប្រតិភូម្នាក់ជាអ្នកដឹកនាំ។

តាមប្រសាសន៍លោក ឯម ហៀង ជាអនុប្រធានអចិន្ត្រៃយ៍នៃលេខាធិការដ្ឋានសហព័ន្ធកីឡាប៊ូល និងប៉េតង់កម្ពុជាបានឱ្យដឹងថា សំរាប់ការប្រកួតពានរង្វាន់ Pan Pacific លើកនេះ លោកក៏បានធ្វើការប្រមូលផ្ដុំនូវកីឡាករ ដែលជាជំរើសជាតិនៅឆ្នាំ២០០៤ និងកីឡាករដែលធ្លាប់ជាប់ជំរើសជាតិពីមុនៗយកមកធ្វើការបង្វឹកហាត់ចាប់ពីថ្ងៃ ១កុម្ភៈ រហូតដល់ថ្ងៃចេញទៅប្រកួត។ ទន្ទឹមគ្នានេះដែរ កញ្ញា អ៊ុក ស្រីមុំ ជាកីឡាការិនីជំរើសជាតិនិយាយថា: "ខ្ញុំមិនអាចស្មានដឹងអំពីលទ្ធផលដែលនឹងទទួលបាននោះទេ។ ប៉ុន្តែខ្ញុំនឹងខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីដណ្ដើមមេដាយជូនជាតិ"។

ជាទូទៅនៅរាល់ពេលប្រកួតពានរង្វាន់ម្ដងៗ កីឡាករម្នាក់ៗត្រូវមានគុណសម្បត្តិសមស្រប ទើបអាចទៅចូលរួមប្រកួតបាន។ កីឡាករនោះត្រូវតែមានសមត្ថភាព និងបទពិសោធន៍ល្អៗគួបផ្សំទៅនឹងអត្តចរិកល្អប្រពៃផងដែរ។

ផាត សំភី

## របៀបលេងកីឡាប៉េតង់

លើទីធ្លាល្បែង កីឡាករប៉េតង់ត្រូវគូសរង្វង់១រួចឈរនៅក្នុងរង្វង់នោះ។ គាត់ត្រូវចោលដុំប៊ូលដែកសំដៅទៅរកគ្រាប់ឃ្លីតូចដែលនៅខាងមុខ។ពេលចោលមិនត្រូវឱ្យជើងហើបចេញពីរង្វង់ឡើយ។ ក្រុមកីឡាករដែលឈ្នះគឺក្រុមដែលចោលប៊ូលបានទៅជិតគ្រាប់ឃ្លីជាងគេ។



# ក្រុមវាលស្រែពញ្ញាក់សង្គម

**សព្វថ្ងៃនេះ សិល្បៈចំរៀងមានប្រជាប្រិយភាពយ៉ាងខ្លាំងសំរាប់ស្រទាប់យុវវ័យ។ ក្នុងចំណោមផលិតកម្មចំរៀងនានាជាច្រើន ក្រុមវាលស្រែបានបង្ហាញចេញនូវចរិកលក្ខណៈដោយឡែករបស់ខ្លួន។**

ក្រុមវាលស្រែតែងប្រើប្រាស់ហ្គីតា ជាឧបករណ៍ដ៏សំខាន់ក្នុងការប្រគុំតន្ត្រីរបស់ខ្លួន ព្រមជាមួយនឹងការច្រៀងបទចំរៀងដែលអត្ថន័យមិនផ្ដោតទៅលើរឿងស្នេហាជាសំខាន់ទេ។

លោក កាន សុពណ៌ ដែលជាសមាជិកម្នាក់របស់ក្រុមវាលស្រែបានបង្ហើបឱ្យដឹងថា អាល់ប៊ុមចំរៀងថ្មីទី២ នឹងចេញផ្សាយនៅថ្ងៃ២៣ ឬ២៤ខែមិនា ឆ្នាំ២០០៥។ នេះគឺជាអាល់ប៊ុម មួយដែលរួមមានទាំងអស់ ២៤បទ ដែលក្នុងនោះមាន ២CD (ថាសចំរៀង) មានទាំងភាសាខ្មែរ និងភាសាបារាំង។ មុននឹងចេញផ្សាយនូវអាល់ប៊ុមថ្មីនេះ ក្រុមវាលស្រែនឹងធ្វើការប្រគុំតន្ត្រីមួយនៅមជ្ឈមណ្ឌលវប្បធម៌បារាំង ហើយនឹងលក់អាល់ប៊ុមចំរៀងដំបូងនៅថ្ងៃនោះតែម្ដង ដោយលក់ក្នុងតំលៃប្រហែលបីដុល្លារ។ លោក ហុង សីហា សមាជិកក្រុមមួយរូបទៀតនិយាយថា: "សំរាប់អាល់ប៊ុមថ្មីនេះ អត្ថន័យនៃបទចំរៀង គឺមានរៀបរាប់អំពីរឿងរ៉ាវប្រវត្តិសាស្ត្រ បរិស្ថាន និងបញ្ហាពិតៗដែលកើតមានក្នុងសង្គម និងស្នេហាក្នុងន័យអប់រំ។ល។ និង។ល។ យើងតែងរបៀបនេះដើម្បីធ្វើឱ្យមានការលាយឡំនូវគ្រប់រសជាតិសំរាប់បទចំរៀងទាំងអស់ ក្នុងគោលបំណងរំលឹកដល់ជនជាតិខ្មែរយើងទាំងអស់គ្នាឱ្យចូលរួមថែរក្សាសម្បត្តិធម្មជាតិដ៏មានតំលៃឱ្យនៅគង់វង្ស"។

ជាទូទៅ អាល់ប៊ុលចំរៀងរបស់ក្រុមវាលស្រែច្រើនមានលក់នៅតាមបណ្ដាហាងនៅក្នុងផ្សារធំៗ ដូចជា ផ្សារសូរិយា ឬ ទួលទំពូងជាដើម ដោយមិនមានលក់នៅតាមតូបតូចៗទេ។ ទោះជាយ៉ាងនេះក្ដី លោក កាន សុពណ៌ បន្ថែមថា ក្រុមលោកត្រូវចំណាយពេលវេលាច្រើន ក្នុងការនិពន្ធបទភ្លេងទំនុកច្រៀង និងសម្ដែងរួមគ្នា។ ប៉ុន្តែ វាមិនបានឱ្យនូវផលចំណេញអ្វីទេ។ តាមពិត កិច្ចការនេះគឺធ្វើឡើងដោយសារទឹកចិត្ត និងឆន្ទៈចង់ឱ្យប្រិយមិត្តបានស្ដាប់ចំរៀង និងឃើញ ឃ្លា[illegible]

ផាត សំភី

## ប្រវត្តិរបស់ក្រុមវាលស្រែ

លោក Phillips វិស្វករសំលេងជនជាតិបារាំងបានឃើញយុវនិស្សិតហុងសីហាច្រៀងចំរៀងនៅមជ្ឈមណ្ឌលវប្បធម៌បារាំង។ អ្នកទាំងពីរបានជួបពិគ្រោះយោបល់គ្នាថាគួរតែបង្កើតក្រុមតន្ត្រីមួយឱ្យខុសប្លែកពីគេ។ ដូច្នេះ ក្រុមវាលស្រែក៏ដំណើរការតាំងពីខែវិច្ឆិកាឆ្នាំ២០០៣មក។



Photo: Sopor

ក្រុមវាលស្រែកំពុងប្រគុំតន្ត្រីនៅវិទ្យាល័យមុនីវង្សឱ្យសិស្សមើលកំសាន្តនៅឯទីរួមខេត្តបាត់ដំបង

## មុខរបរ

**ការងារសំអាងការកំពុងមានការទទួលស្គាល់ច្រើនពីក្រុមយុវនារី។ អាជីពនេះមិនជាងាយស្រួលនោះទេសំរាប់អ្នកកំពុងសិក្សា និងអ្នកដែលប្រកបរបរនេះដោយផ្ទាល់នោះ។**



Photo: Kunthear

# អ្នកសំអាងការ

### ការងារ

នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ជាចាំបាច់តម្រូវឱ្យមានអ្នកសំអាងការដើម្បីរៀបចំតុបតែងមុខមាត់ សម្លៀកបំពាក់ឱ្យដល់កូនកំលោះ និងកូនក្រមុំ។ ការងារនេះភាគច្រើនជាការងាររបស់មនុស្សស្រី ពីព្រោះវាជាការងារមួយដែលតម្រូវឱ្យអ្នកធ្វើត្រូវមានចិត្តអត់ធ្មត់ តស៊ូ និងផ្ចិតផ្ចង់ជានិច្ច។ ម្យ៉ាងទៀត អ្នកសំអាងការក៏តម្រូវឱ្យចេះមានគំនិតច្នៃប្រឌិតផងដែរ។ នៅពេលដែលចង់បំពេញចិត្តរបស់អតិថិជន ឱ្យមានការពេញចិត្តលើការងាររបស់ខ្លួន អ្នកសំអាងការត្រូវតាំងចិត្តធ្វើតាមតម្រូវការ ឬតាមការសំណូមពររបស់អតិថិជននោះជានិច្ចដោយមិនអាចប្រកែកបានឡើយ។ អ្នកនាង គ្រុយ សុខ កញ្ញា ម្ចាស់ហាងសំអាងការពន្លឺពេជ្រ ដែលមានបទពិសោធន៍ជាង១០ឆ្នាំមកហើយនោះ មានប្រសាសន៍ថា: "ការដែលហាងខ្ញុំនៅតែទទួលបានការពេញចិត្តពីភ្ញៀវរហូតមកដល់សព្វថ្ងៃដោយសារខ្ញុំតែងមានការអត់ធ្មត់ទាំងពាក្យសំដី ទាំងការងារ និងចេះសម្របសម្រួលជាមួយពួកគេ"។

### ផលទទួលបាន

ក្នុងមួយខែៗ អ្នកសំអាងការអាចរកចំណូលបាន ជាមធ្យមពី៣០០ទៅ ៤០០ដុល្លារ ក្នុងមួយរដូវរៀបការ។ ក្នុងមួយរោងការ អ្នកសំអាងអាចរកចំណូលបាន យ៉ាងហោចណាស់ក៏ ៤០០ដុល្លារ ដែរ។ ចំពោះតំលៃនៃការជួលសំអាងការ គឺមានការខុសៗគ្នា មានពី៣០០ទៅ ៧០០ដុល្លារ គឺអាស្រ័យទៅតាមសម្លៀកបំពាក់ចាស់ ឬថ្មី។

### ព័ត៌មានសិក្សា

ដើម្បីឱ្យបានក្លាយខ្លួនទៅជាអ្នកសំអាងការដែលមានជំនាញខ្ពស់ គេតម្រូវឱ្យមានការសិក្សាឱ្យបានច្បាស់លាស់។ គេត្រូវស្វែងរកសាលាដែលមានគ្រូមានជំនាញខ្ពស់ និងបទពិសោធន៍ច្រើនឆ្នាំ។ តំលៃ ៥០០ដុល្លារ សំរាប់១វគ្គសិក្សាសំអាងការធានាថា នៅពេលរៀនចប់ អ្នកនឹងអាចយកចំណេះទៅប្រ[illegible]

មុំ គន្ធា

## សាលាសិក្សាសំអាងការ

សំអាងការពន្លឺពេជ្រ ០១២ ៨៨៣ ២៨៤។

សំអាងការ ចាន់ណាទាន់សម័យ។ ទូរស័ព្ទ: ០១២ ៤០៣ ៧៥៥។

សំអាងការ អប្សរាឌីយ៉ាម៉ង់។ ទូរស័ព្ទ: ០១២ ៨៦៦ ១៩៣។

## នៅពេលនេះ “អ្នកនាំសារ” សូមបង្ហាញជូនប្អូនៗ អំពីរបៀបធ្វើស៊ុមរូបថតដ៏ងាយស្រួលមួយ ដើម្បីឱ្យប្អូនៗ អាចប្រើប្រាស់ស៊ុមនេះដាក់រូបថតណាមួយក៏បានឱ្យតែប្អូនស្រលាញ់ពេញចិត្ត។

១





សំភារៈដែលត្រូវមាន:
ក្រដាសកាតុងពណ៌ស
កូនកាំបិត បន្ទាត់
ខ្មៅដៃ និង កាវ។

១. កាត់ក្រដាសរាងចតុកោណកែង ២ សន្លឹកប្រវែង ១៥សម គុណ ២១សម។

២. ដាក់រូបថតនៅចំកណ្ដាលកាតុងទី១ ហើយគូសស្នាមតាមទំហំរូបថត រួចកាត់ទៅតាមស្នាមនោះ។

២



៣



៤



៥



៣. ដាក់ក្រដាសទី១ លើក្រដាសទី២ ហើយគូសតាមស្នាម ដែលបានកាត់រួច មកហើយនោះ។

៤. យកកាវបិទរូបថតលើក្រដាសទី២ តាមស្នាម ដែលបានគូសទុក រួចបិទក្រដាសទី១ លើក្រដាសទី២។

៥. កាត់ក្រដាសប្រវែង ២១សម គុណ ៦សម។ រួចបត់ត្រឹម ៦សម ហើយបិទភ្ជាប់លើ ខ្នងស៊ុមរូបថត។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៩២ សង្កាត់ បឹងព្រលិត រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ អូមែរ ហ្សឺរ៉ាល់ដូ